# ឌុច និងសាក្សីជំនាញយល់ស្របគ្នាពីរចនាសម្ព័ន្ធទំនាក់ទំនងរបស់ខ្មែរក្រហម ប៉ុន្តែមិនយល់ស្របទាក់ទិននឹងការទទួលខុសត្រូវ

ដោយ ឡូរ៉ា ម៉ាក់ដូណល់
ថ្ងៃទី២៧ ខសភា ឆ្នាំ២០០៩
ប្រែសម្រួលដោយ ទែន សុខស្រីនិត

## ឌុច ៖ អ្នករងទោសជំនួសអ្នកដទៃ?

ដោយគ្មានការលើកឡើងពីការពិភាក្សាវែកញែកលើភាពលំអៀងរបស់សាក្សីជំនាញ ក្រេក អេតឆេសាន់ ដែលបានបញ្ចប់នៅកាលពីម្សិលមិញ លោកប្រធានចៅក្រម និល ណុន បានផ្ទេរភារកិច្ចទៅឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ អាឡិចសាន់ឌឺ ប៊ើត ដើម្បីចោទសួរជនត្រូវចោទ កាំង ហ្កេកអ៊ាវ (ឌុច) ទាក់ទិននឹងសំបុត្រទាំង៩ច្បាប់ផ្ញើរពីកងពលលេខ៥០២ ដោយអនុលេខា ស៊ូ ម៉េត ទៅឲ្យ ឌុច ។ ដោយកើតឡើងក្នុងកាលបរិច្ឆេទចាប់ពីខែមេសា ដល់ខែវិច្ឆិកា ឆ្នាំ១៩៧៧ សំបុត្រទាំង៩ច្បាប់នោះនិយាយពីចម្លើយសារភាព និងការចាប់ខ្លួន“ជនក្បត់”របស់ខ្មែរក្រហមក្នុងចំណោមអ្នកមានតំណែងនៅផ្នែកយោធា និងនិយាយពីការបញ្ជូនរបស់ជនទាំងនោះទៅកាន់គុកទួលស្លែង ដែលត្រូវបានគេស្គាល់ថាជាមន្ទីរស-២១ ។

ទាក់ទិនជាមួយនឹងការឆ្លើយឆ្លងដែលធ្វើឡើងរវាង ឌុច និង ស៊ូ ម៉េត ។ ឌុច បានគូសបញ្ជាក់ និងលើកឡើងម្តងហើយម្តងទៀតនៅក្នុងការធ្វើកសិណសាក្សីថា ខ្លួនមិនមានសិទ្ធិធ្វើការទាក់ទងដោយគ្មានការចាត់តាំងជាមួយនឹងមនុស្សដូចជា ស៊ូ ម៉េត ឬអង្គភាពផ្សេងៗដូចជាកងពលលេខ៥០២នោះទេ ពីព្រោះថា ឌុច អាចនឹងត្រូវសម្លាប់ចោលប្រសិនបើការធ្វើទំនាក់ទំនងរវាងបុគ្គលនិងបុគ្គលតាមខ្សែទទឹងកើតមានឡើង ។ ដូច្នេះ រាល់ទំនាក់ទំនងទាំងអស់ ត្រូវតែធ្វើឡើងតាមរយៈការរាយការណ៍តាមខ្សែបណ្តោយទៅឲ្យមេដែល ឌុច បានធ្វើការទាក់ទងជាប្រចាំជាមួយនឹង សុន សេន ដែលជាឧបនាយរដ្ឋមន្ត្រីការពារជាតិ និងជានាយកអគ្គសេនាធិការរបស់កងទ័ពបដិវត្តន៍កម្ពុជា ។ ឌុច បានឆ្លើយថា រាល់សំបុត្រដែលទទួលបានពី ស៊ូ ម៉េត ដែលផ្ញើរជូនផ្ទាល់មកឲ្យ ឌុច គឺត្រូវបានប្រគល់ឲ្យ ឌុច ដោយដៃ សុន សេន ផ្ទាល់ ។ សំបុត្រខ្លះមានការកត់ត្រាដោយដៃបន្ថែមដែលនេះបានគូសបញ្ជាក់ថា តាមពិតទៅ

សំបុត្រទាំងនេះបានឆ្លងកាត់ សុន សេន រួចហើយ ប៉ុន្តែក៏មានសំបុត្រផ្សេងទៀតដែលមិនមានការកត់ត្រាបន្ថែម ។ ឌុច បានពន្យល់ប្រាប់ថា ខ្មែរក្រហមមានគោលនយោបាយមួយ ធ្វើការលាក់បាំងឈ្មោះសមាជិកបក្សដែលមានតំណែងជាន់ខ្ពស់ ដើម្បីជាសញ្ញាណបង្ហាញឲ្យឃើញនូវសេចក្តីគោរព និងដើម្បីរក្សាការសម្ងាត់ ។ ឌុច បាននិយាយថា ឌុច មិនហ៊ានប្រាប់ឈ្មោះ សុន សេន ឬ នួន ជា នៅក្នុងសំបុត្រទេ ។ ជាសរុបមក សំបុត្រមួយច្បាប់ដែលផ្ញើដោយសមាជិកបក្សថ្នាក់កណ្តាល “ក” ជូនទៅឲ្យសមាជិកបក្សថ្នាក់កណ្តាល “ខ” តែងតែឆ្លងកាត់មន្ត្រីបក្សដែលមានតំណែងខ្ពស់ “គ” ប៉ុន្តែជាទូទៅមិនមានការលើកឡើងពីឈ្មោះមន្ត្រីថ្នាក់ខ្ពស់ “គ” នៅក្នុងសំបុត្រឡើយ ។

ឌុច បានឆ្លើយថា ខ្លួនបានរៀបចំបញ្ជីឈ្មោះជនក្បត់ចេញពីចម្លើយសារភាពរបស់អ្នកទោស មន្ទីរស-២១ ហើយបញ្ជូនទៅឲ្យ សុន សេន ។ ក្រោយមក សុន សេន ធ្វើការពិនិត្យ និងទទួលស្គាល់បញ្ជីឈ្មោះនេះមុននឹងបញ្ជាឲ្យមេដឹកនាំអង្គភាពសំខាន់ផ្សេងទៀត ដូចជា ស៊ូ ម៉េត ធ្វើការចាប់ខ្លួនមនុស្សដែលមានឈ្មោះក្នុងបញ្ជី ហើយបញ្ជូនទៅកាន់មន្ទីរស-២១ ។ បើទោះបីជាតាមន័យរបស់សំបុត្រនេះទំនងជាប្រាប់ថា ឌុច បានចូលរួមដោយផ្ទាល់នៅក្នុងការជ្រើសរើសមនុស្សដែលត្រូវបញ្ជូនមកកាន់មន្ទីរស-២១ក៏ដោយ ក៏ ឌុច បានឆ្លើយថា ខ្លួនមិនមានអំណាចចេញសេចក្តីសម្រេចមិនដូច សុន សេន ដែលមានអំណាចចេញបញ្ជាកម្ទេច“ជនក្បត់” ហើយចំណែកឯ ស៊ូ ម៉េត ដែលមានអំណាចចាប់ខ្លួនមនុស្សទាំងនោះទេ ។ ឌុច បានអះអាងថា តួនាទីតែមួយគត់របស់ខ្លួនគឺ សួរចម្លើយ និងទាញយកចម្លើយសារភាពតែប៉ុណ្ណោះ ។ បើទោះបីជា ឌុច បានទទួលស្គាល់ថា របាយការណ៍របស់ខ្លួនមានឥទ្ធិពលលើថ្នាក់លើដោយសារតែថ្នាក់លើទាំងនោះជឿទុកចិត្តលើ ឌុច ក៏ដោយ ក៏ ឌុច បានអះអាងថា ខ្លួនគ្រាន់តែឆ្លើយនឹងសំណួរ និងធ្វើតាមបញ្ជាថ្នាក់លើតែប៉ុណ្ណោះ ដោយនិយាយថា ការទទួលខុសត្រូវគឺស្ថិតនៅលើថ្នាក់លើ ។

មេធាវីការពារក្តីមិនបានចោទជាសំណួរទៅកាន់ ឌុច ឡើយ ប៉ុន្តែបានចែករំលែកនូវការអង្កេតរបស់ខ្លួន ។ ការ សាវុត្ថ មេធាវីការពារក្តីជាតិ បានលើកឡើងពីសេចក្តីជំទាស់មួយដែលស៊ីពេល ហើយទង្វើរនេះត្រូវបានធ្វើឡើងម្តងទៀតដោយមេធាវីការពារក្តីដដែលដោយអះអាងថា ៖ ដំណើរការស៊ើបអង្កេតរបស់សំណុំរឿងមិនត្រូវបានគោរពតាមដោយភាគីទាំងអស់ឡើយ ពីព្រោះថា ភាគីទាំងអស់បានកំពុងតែចោទសួរសាក្សី និង ឌុច ពីបញ្ហាដែលត្រូវបានស្វែងរកឃើញយ៉ាងពេញលេញរួចទៅហើយដោយសហចៅក្រមស៊ើបអង្កេត ។ ហ្វ្រង់ស័រ រូ បានគូសបញ្ជាក់បន្ថែមទៀតថា ព្រះរាជអាជ្ញាគួរតែកោះ

ហៅ ស៊ូ ម៉េត ក្នុងអំឡុងដំណើរការស៊ើបអង្កេតរបស់សំណុំរឿងដើម្បីពិភាក្សាពីសំបុត្រទាំងនោះដែល ស៊ូ ម៉េត ផ្ទាល់បានសរសេរមិនមែន ឌុច ទេ។ ហ្វ្រង់ស៊័រ រូ បានចោទជាសំណួរថា ៖ តើ ឌុច មិនមែនត្រូវបានប្រើប្រាស់ជាជនដែលរងទោសជំនួសអ្នកដទៃមែនឬ?

## លោកបណ្ឌិត ក្រេក អេតឆេសាន់ ៖ ទំនាក់ទំនងតាមរយៈខ្សែបណ្តោយជាមួយនឹងការទទួលខុសត្រូវរួម

បន្ទាប់ពីការឈប់សម្រាកអាហារថ្ងៃត្រង់មក ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានចោទសួរសាក្សីជំនាញពីខ្មែរក្រហមគឺ ក្រេក អេតឆេសាន់។ បើយោងទៅតាមកសិណសាក្សីរបស់លោកកាលពីសប្តាហ៍មុន ក្រេក អេតឆេសាន់ បានបញ្ជាក់កសិណសាក្សីរបស់ ឌុច ទាក់ទិននឹងរចនាសម្ព័ន្ធទំនាក់ទំនងតាមរយៈខ្សែបណ្តោយ ដែលត្រូវបានអនុវត្តយ៉ាងហ្មត់ចត់ដោយខ្មែរក្រហម ហើយពន្យល់ថា មជ្ឈិមបក្សធ្វើបែបនេះ ដើម្បីរក្សានូវការក្តោបព័ត៌មានឲ្យបាន។

ក្រេក អេតឆេសាន់ បានរៀបរាប់ពីមុខតំណែង និងតួនាទីដ៏សំខាន់របស់មន្ទីរស-២១ក្នុងចំណោមមន្ទីរសន្តិសុខរបស់ខ្មែរក្រហមដទៃទៀត។ មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខ តែមួយគត់ដែលមានអំណាចសម្រេចកម្ទេចសមាជិកបក្សជាន់ខ្ពស់ ដែលសង្ស័យថាជាជនក្បត់ ហើយក៏មានអំណាចសម្រេចឃុំខ្លួនធ្វើទារុណកម្ម និងសម្លាប់មនុស្ស ដែលត្រូវបានចាប់ខ្លួនទូទាំងប្រទេសផងដែរ។ បន្ថែមលើនេះ លោកក៏បានកត់សម្គាល់ថា មន្ទីរស-២១ធ្លាប់មានបុគ្គលិកចំនួន ២,៣២៧នាក់ ផ្ទុយពីមន្ទីរសន្តិសុខផ្សេងទៀតដែលមានបុគ្គលិកយ៉ាងច្រើនបំផុតត្រឹមតែ ៥០នាក់ប៉ុណ្ណោះ។ តាមរចនាសម្ព័ន្ធ ក្រេក អេតឆេសាន់ បានពន្យល់ប្រាប់ថា មន្ទីរស-២១ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការយោធា ប៉ុន្តែតាមគោលការណ៍មន្ទីរស-២១ គឺជាអង្គភាពដែលក្រោមបង្គាប់របស់គណៈមជ្ឈិម ។

ដោយធ្វើការកត់សម្គាល់ពីបញ្ហាការទទួលខុសត្រូវចម្បង ក្រេក អេតឆេសាន់ បាននិយាយថា ក្នុងកាលៈទេសៈខ្លះការបោសសម្អាតក្នុងជួរបក្សត្រូវបានធ្វើឡើងដោយរោគឆ្កួតរបស់គណៈមជ្ឈិម ប៉ុន្តែក្នុងកាលៈទេសៈផ្សេងទៀតការបោសសម្អាតនេះ គឺបណ្តាលមកពីវិធីសាស្ត្រដែលអនុវត្តដោយ ឌុច។ បន្ថែមលើនេះ លោកបានបង្ហាញពីការជឿងឆ្ងល់ដែលថា សុន សេន អាចនឹងទទួលស្គាល់ឈ្មោះមនុស្សទាំងអស់នោះដែលត្រូវកម្ទេច ដូចដែល ឌុច បានអះអាងក្នុងអង្គជំនុំជម្រះកាលពីពេលព្រឹកនោះ

មែនឬទេ ។ លោកបាននិយាយថា សុន សេន អាចនឹងមានចំណាប់អារម្មណ៍លើមនុស្សដែលមានមុខតំណែងខ្ពស់ ឬក៏មនុស្សសំខាន់ៗដែលត្រូវកម្ទេចតែប៉ុណ្ណោះ ។ ប៉ុន្តែដោយសារតែតំណែងជាន់ខ្ពស់ និងកាតព្វកិច្ចដ៏រវល់របស់ សុន សេន វាទំនងជាថា សុន សេន ចេញសេចក្តីសម្រេចកម្ទេចមនុស្ស ។ សេចក្តីសន្និដ្ឋាននេះគួរបញ្ជាក់ថា ជនក្បត់មួយភាគធំដែលមិនមែនជាមនុស្ស“សំខាន់” ឌុច គឺជាអ្នកចេញសេចក្តីសម្រេចថា តើនរណានឹងត្រូវបោសសម្អាតចោលដោយផ្អែកទៅតាមមូលដ្ឋានចម្លើយសារភាពរបស់មន្ទីរស-២១ ។

ក្រេក អេតឆេសាន់ នឹងត្រូវមកបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះម្តងទៀតនៅថ្ងៃស្អែក ដើម្បីឲ្យមេធាវីការពារក្តី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមទៀតធ្វើការចោទសួរ ។

## សហចៅក្រមស៊ើបអង្កេតនិយាយក្នុងឱកាសសន្និសីទកាសែត

ផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរៀបចំធ្វើសន្និសីទកាសែតមួយដែលមានការចូលរួមដ៏ច្រើនកុះករកាលពីពេលរសៀលនេះ ដែលសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង ម៉ាសែល ឡឺម៉ុង់ ធ្វើការពិភាក្សាពីដំណើរការស៊ើបអង្កេតសំណុំរឿងលេខ០០២ ទាក់ទិននឹងជនត្រូវចោទ នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ។ ដោយធ្វើការកត់សម្គាល់ពីភាពស្មុគស្មាញរបស់សំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេតទាំងពីររូបបានបង្ហាញពីគោលដៅ“ដ៏មុតមាំ” របស់ខ្លួនក្នុងការបញ្ចប់ការស៊ើបអង្កេតបឋមនាចុងឆ្នាំ២០០៩នេះ ។ ក្រោយពីការស៊ើបអង្កេតបឋមបានបញ្ចប់ទៅ ភាគីដែលចូលរួមក្នុងដំណើរការនីតិវិធី អាចស្នើរសុំឲ្យមានសកម្មភាពស៊ើបអង្កេតបន្ថែមទៀត ហើយប្រសិនបើសំណើរនេះត្រូវបានបដិសេធនោះភាគីទាំងអស់អាចធ្វើការតវ៉ាទៅអង្គបុរេជំនុំជម្រះបាន ។ សហចៅក្រមស៊ើបអង្កេតបាននិយាយថា បន្ទាប់ពីការស៊ើបអង្កេតបានបញ្ចប់ ការពន្យាពេលដែលកើតឡើងដោយសារមូលហេតុបែបនេះ មិនមែនជាការទទួលខុសត្រូវរបស់សហចៅក្រមស៊ើបអង្កេតនោះទេ ។

សហចៅក្រមស៊ើបអង្កេតបានរាយការណ៍ថា សាក្សីចំនួន៤៥៣នាក់ត្រូវបានធ្វើបទសម្ភាសន៍ ចាប់តាំងពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩មក រួមទាំងជនជាតិបរទេសខ្លះផងដែរ ។ ដោយចូលរួមចំណែកក្នុងការស៊ើបអង្កេត មេធាវីរបស់ជនត្រូវចោទទាំងបួនរូបក៏ត្រូវបានធ្វើការទាក់ទង ប៉ុន្តែមេធាវីទាំងអស់

នោះបែរជាអនុវត្តសិទ្ធិមិនឆ្លើយតបរបស់ខ្លួនទៅវិញ ។ សហចៅក្រមស៊ើបអង្កេតបានពន្យល់ប្រាប់ថា ការស៊ើបអង្កេតនេះ តាមពិតទៅមិនមានលក្ខណៈដាច់ដោយឡែកពីការស៊ើបអង្កេតផ្សេងទៀតនោះទេ ហើយវាអាចមានសេចក្តីសម្រេចមួយដើម្បីដាក់សំណុំរឿងទាំងអស់នេះរួមគ្នាក៏ថាបាន ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេត បានបដិសេធមិនបញ្ចេញយោបល់លើបញ្ហាថា តើការទទួលខុសត្រូវរួមគ្នាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម នឹងអាចយកមកពិចារណានៅក្នុងសំណុំរឿងដែលនឹងត្រូវដាក់រួមគ្នានេះដែរឬយ៉ាងណានោះទេ ។